**សេចក្តីប្រកាសព័ត៌មាន**

**ស្តីពី**

**វគ្គបណ្តុះបណ្តាល និងការផ្សព្វផ្សាយ**

**"ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយ**

**អាវុធមហាប្រល័យ (AML/CFT/CPF)"**

ថ្ងៃអង្គារ ៦កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣

នារសៀលថ្ងៃអង្គារ ៦កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ នៅអគារមជ្ឈមណ្ឌលធុរកិច្ច **និយ័តករបរធនបាលកិច្ច (ន.ប.ធ)** បានរៀបចំវគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយ"ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយ អាវុធមហាប្រល័យ(AML/CFT/CPF)" ដោយបញ្ចូលប្រធានបទក្នុងកម្មវិធីបណ្តុះបណ្តាល និងការប្រលងសម្រាប់ បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៣ ឆ្នាំ២០២៣។

ការបញ្ចូលកម្មវិធីក្នុងវគ្គបណ្តុះបណ្តាលនេះ ធ្វើឡើងក្នុងគោលបំណងដើម្បីបណ្តុះបណ្តាលដល់បុគ្គល រាយការណ៍និងបុគ្គលពាក់ព័ន្ធផ្សេងទៀត ដើម្បីបញ្ជ្រាបការយល់ដឹងអំពី "ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (AML/CFT/CPF)" ដែល មានសមាសភាពចូលរួមដោយផ្ទាល់ពី តំណាងក្រុមហ៊ុនបរធនបាល ប្រតិបត្តិករបរធនបាល ក្រុមហ៊ុនវាយតម្លៃ ក្នុងវិស័យបរធនបាលកិច្ច និងសាធារណជន សរុបចំនួន **១៥០** នាក់។

On the afternoon of Tuesday, August 22, 2023, at the Business Development Center, the Trust Regulator (TR) had incorporated a Training Program and Dissemination on the "Law on Combating Money Laundering and Financing of Terrorism, Combating Financing of Proliferation of Weapons of Mass Destruction (AML/CFT/CPF)" in the 3rd Training Program and Examination for Approved Persons in the Trust Sector of 2023.

The purpose of incorporating such a Training Program is to raise awareness of "Law on Combating Money Laundering and Financing of Terrorism, Combating Financing of Proliferation of Weapons of Mass Destruction (AML/CFT/CPF)", with a total of 150 participants who are Trustees, Evaluation Companies, Trustee Companies, and the public attending the training programe.